# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១. ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៣៩៥/៣១
### ស្តីអំពីការតែងតាំងប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាល
### នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស**
**ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានទ្រង់យល់ព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលសកម្មភាព កំចាត់មីនកម្ពុជា ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣
- បានទ្រង់យល់សេចក្តីអនុម័តទុកចិត្តរបស់រដ្ឋសភា ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ លើសំណើរបស់ រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីអំពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ចុះថ្ងៃទី ខែ កុម្ភៈ ឆ្នាំ ១៩៩៥

តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដូចខាងក្រោមនេះ ÷

| | |
|---|---|
| ១_ឯកឧត្តម **អៀង មូលី** | ជាប្រធានក្រុមប្រឹក្សាភិបាល |
| ២_ឯកឧត្តម **ហុង ស៊ុនហួត** | សមាជិក |
| ៣_ឯកឧត្តម **ឯក សិរីវឌ្ឍន៍** | សមាជិក |
| ៤_ឯកឧត្តម **អ៊ឹម ឈុនលឹម** | សមាជិក |
| ៥_ឯកឧត្តម **ស៊ិន ចាន់ថុល** | សមាជិក |
| ៦_ឧត្តមសេនីយ៍ទោ **លី សេងហុង** | សមាជិក |
| ៧_ឯកឧត្តម **អ៊ុច គីមអន** | សមាជិក |
| ៨_ ឯកឧត្តម **ឈៀង យ៉ាណារ៉ា** | សមាជិក |
| ៩_ឯកឧត្តម **លី ធុច** | សមាជិក |

**មាត្រា ២ :** នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ មិនា ឆ្នាំ ១៩៩៥*

ព្រះហស្តលេខា

**នរោត្តម សីហនុ**

* * *

## ព្រះរាជក្រឹត្យ នស/រកត/០៣៩៥/៣២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម